*ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣*

# ការប្រឈមរបស់ស្ត្រីចូលរួមក្នុងឆាកនយោបាយ និង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ឆ្នាំ២០១៣

ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ កំពុងប្រឈមនឹងកង្វះខាតឋវិកានយោបាយ និងគោលនយោបាយលើកស្ទួយស្ត្រីជាលាយលក្ខណ៍អក្សរ ព្រមទាំងឧបសគ្គរបស់អ្នកបោះឆ្នោតស្ត្រីរាប់ចាប់ពីដំណើរការចុះឈ្មោះបោះឆ្នោត ឱកាសក្នុងការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ និងការចូលរួមបោះឆ្នោត ។

សកម្មភាពនយោបាយនៅតែស្ថិតនៅក្នុងស្ថានភាពតូចចង្អៀត និងប្រឈមសម្រាប់ស្ត្រីក្នុងការទទួលបានឱកាសចូលរួមប្រកួតប្រជែងឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោតខាងមុខនេះ ។ គណបក្សនយោបាយមួយចំនួនដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥នេះ បានលើកឡើងអំពីតំរូវការថវិការបស់គណបក្សទាក់ទិននឹងការតែងតាំងបេក្ខជនឈរឈ្មោះ ។ បើសិនជាសមាជិកគណបក្សមានលុយ (មានលទ្ធភាព) ទើបពួកគេមានឱកាសបានឈរឈ្មោះជាបេក្ខជន រួមបញ្ចូលជាមួយនឹងលក្ខខណ្ឌមួយចំនួនដូចជា បេក្ខជនត្រូវមានសមត្ថភាព ប្រជាប្រិយភាព ឆន្ទៈមុះមុត និងមានប្រវត្តិនយោបាយយូរ ។ បន្ថែមលើនេះទៀត ខ្វះយន្តការដើម្បីគាំទ្រ និងផ្តល់ឱកាសដែលជាវិធានការពិសេសបណ្តោះអាសន្នសម្រាប់លើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ ដូចជាគ្មានគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្ស និងនៅក្នុងច្បាប់បោះឆ្នោតជាដើម ។ ការខ្វះនូវគោលនយោបាយ និងលក្ខខណ្ឌដែលបានលើកឡើងទាំងនេះជាឧបសគ្គ និងជាការប្រឈមមួយដ៏ធំសម្រាប់បេក្ខនារីដែលមានបំណងឈរឈ្មោះដើម្បីឱ្យគេបោះឆ្នោតក្នុងនីតិកាលទី៥នេះ ។ ជាក់ស្តែងថ្មីៗនេះ លទ្ធផលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះ និងបញ្ជីបេក្ខជនបង្ហាញឱ្យឃើញថា ស្ត្រីបានឈរឈ្មោះជាបេក្ខជនមានចំនួនតែ **១៦៨នាក់ (១៨,៩៦%)** នៃចំនួនបេក្ខជន**សរុប ៨៨៦នាក់ និង១២,១៦% ឈរឈ្មោះពីលេខរៀងទី១ ដល់ទី៣** មកពី **៨**គណបក្សនយោបាយ ។ តួលេខនេះមានការ**កើន ៤,១៦%** ពី ១៤,៨0% (អាណត្តិទី៤ ឆ្នាំ២០០៨) ទៅ ១៨,៩៦% (អាណត្តិទី៥ ឆ្នាំ២០១៣) ទោះជាមានការកើនឡើងខ្លះ ក៏ដោយវានៅតែជាចំនួនតិចតួចនៅឡើយ ។ គណបក្ស២ ដែលមានប្រជាប្រិយភាពជាងគេ ដូចជា គណបក្សប្រជាជនកម្ពុជា បានដាក់បេក្ខជនស្ត្រីចំនួនតែ ២0រូប (១៦,២៦%) ដូចគ្នានឹងអាណត្តិទី៤ ឆ្នាំ២០០៨ និងគណបក្សសង្គ្រោះជាតិបាន ដាក់បេក្ខជនស្ត្រីចំនួន ១២រូប (៩,៧៥%) ដែលជាចំនួនតិចតួចឃ្លាតឆ្ងាយពីអ្វីដែលសង្គមស៊ីវិលស្នើឱ្យដាក់បេក្ខជនស្ត្រីឈរឈ្មោះយ៉ាងហោច៣0% សម្រាប់ការបោះឆ្នោតជាតិ នីតិកាលទី៥នេះ ។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

យោងតាមករណីសិក្សារបស់ខុមហ្វ្រែលថ្មីៗនេះបានរកឃើញថា ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក៏មានភាពមិនប្រក្រតីទាក់ទិនទៅនឹងការមិនគោរពនីតិវិធី ដូចជា ការមិនគោរពពេលវេលាធ្វើការដែលជាផលប៉ះពាល់ទៅលើប្រជាពលរដ្ឋជាស្ត្រីមួយចំនួន។ ជាក់ស្តែង ករណីនៅសង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ស្ត្រីភាគច្រើននៅសង្កាត់វាលវង់ជាអ្នកលក់ដូរ ពួកគាត់រវល់លក់ដូរនៅផ្សារមិនសូវមានពេលទំនេរសំរាកលុះដល់ទំនេរពី ការលក់ដូរនៅម៉ោង ៤:០០ រសៀល ដល់ ៥:០០ ល្ងាច ទើបពួកគាត់បានទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ក៏ប៉ុន្តែពេលដែលពួកគាត់បានទៅដល់ការិយាល័យចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះ មន្ត្រីបំរើការចុះឈ្មោះអ្នកបោះឆ្នោតនៅទីនោះ បានបិទទ្វារសំរាកពីការងារទៅហើយ ដូច្នេះពួកគាត់ពិបាកសួរនាំព័ត៌មានទាក់ទិននឹងការពិនិត្យបញ្ជីឈ្មោះ និងអ្នកខ្លះមិនបានចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០១២ នេះក៏ជាមូលហេតុមួយរារាំងស្ត្រីមិនឱ្យចូលរួមក្នុងការបោះឆ្នោតដែលជាការប៉ះពាល់សិទ្ធិនយោបាយរបស់ម្ចាស់ឆ្នោត។ ករណីសិក្សា និងរបាយការណ៍សង្កេតការណ៍អំពីស្ត្រីនៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២បានរកឃើញទៀតថា ស្ត្រីមួយចំនួននៅក្នុងឃុំ សង្កាត់ ស្រុក ក្រុងចំនួន១០ មានដូចជា *សង្កាត់បារាយណ៍ និងសង្កាត់រកាក្នុង (ក្រុងដូនកែវ ខេត្តតាកែវ) សង្កាត់កំពង់ប្រណាក និង សង្កាត់ប៉ាលហាល (ក្រុងព្រះវិហារ ខេត្តព្រះវិហារ) ឃុំក្តីដូង (ស្រុកកំពង់ស្វាយ) និង សង្កាត់ដំរីជាន់ខ្លា (ក្រុងស្ទឹងសែន ខេត្តកំពង់ធំ) សង្កាត់វាលវង់ និងសង្កាត់សំបួរមាស (ក្រុងកំពង់ចាម ខេត្តកំពង់ចាម) សង្កាត់ប្អេរ និងសង្កាត់ផ្សារឆ្នាំង (ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង)* មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការទទួលព័ត៌មានឱ្យបានទូលំទូលាយ អំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ ដោយសារស្ត្រីជាមេផ្ទះរវល់តែនឹងកិច្ចការផ្ទះ និងស្ត្រីមួយចំនួន ទៀតរវល់តែនឹងមុខរបរលក់ដូរ។ ពួកគាត់ទាំងនោះមានភាពមមាញឹកក្នុងការមើលថែទាំកូនចៅ និងគ្រួសារ ព្រមទាំងចេញទៅបំពេញការងារតាមតួនាទីរៀងៗខ្លួនដោយពុំសូវបានគិតគូរ ឬព្រួយបារម្ភអំពីសិទ្ធិរបស់ខ្លួនចូលរួមក្នុងដំណើរការបោះឆ្នោតរាប់ចាប់តាំងពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលជាដំណាក់កាលមួយដ៏សំខាន់ដើម្បីឱ្យពួកគាត់មានសិទ្ធិទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

យោងតាមលទ្ធផល SVRA Plus របស់ខុមហ្វ្រែលរកឃើញថា បញ្ជីបោះឆ្នោតមិនទាន់មានគុណភាព និងការលុបឈ្មោះអ្នកបោះឆ្នោតមានភាពមិនប្រក្រតីនៃការអនុវត្តនីតិវិធី។ មាន ១៣,៥០% នៃអ្នកចុះឈ្មោះបោះឆ្នោតដែលមិនមានទិន្នន័យក្នុងបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០១៣ (ឈ្មោះរបស់ពួកគេមិនអាចរកឃើញ ឬឈ្មោះនោះផ្លាស់ប្តូរទាំងស្រុង) ប្រហែលជាង ១,២៥លាននាក់ នៃអ្នកចុះឈ្មោះបោះឆ្នោតក្នុងនោះ មានស្ត្រីប្រមាណ ៦២,៨០% ដែលអាចប្រឈមនឹងការបាត់បង់សិទ្ធិនៅក្នុងការបោះឆ្នោតនាពេលខាងមុខ។

ដូច្នេះ ខុមហ្វ្រែលអាចធ្វើការប្រមើលមើលដោយវាយតម្លៃសន្និដ្ឋានទៅលើការចូលរួមរបស់ស្ត្រីថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ នីតិកាលទី៥ខាងមុខនេះ ចំនួនស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រ**អាចនឹងថយចុះ** និងពុំអាចឈានទៅដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែលបានកំណត់ថា ត្រូវតែមានស្ត្រីក្នុងតួនាទីសំរេចចិត្តនៅថ្នាក់ជាតិចំនួន ៣០% នៅឆ្នាំ២០១៥ (ដោយយោងតាមតួលេខបេក្ខជនស្ត្រីឈរឈ្មោះតិចតួចរបស់គណបក្ស នយោបាយ២ ដែលមានប្រជាប្រិយជាងគេ និង ដោយយោងតាមស្ថានភាពនយោបាយ ករណីសិក្សា និងការសិក្សាស្រាវជ្រាវ

ដែលបានរកឃើញថ្មីៗនេះ) ។ ម្យ៉ាងទៀត ខុមហ្វ្រែល យល់ឃើញថា ប្រសិនបើនៅ ថ្ងៃបោះឆ្នោតនៅតែមានបញ្ហាបាត់ឈ្មោះ ឬមិនអាចរកឃើញឈ្មោះរបស់អ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការបន្តទៀត ខុមហ្វ្រែល អាចប៉ាន់ស្មានការប្រឈមនឹងការបាត់បង់សិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោតជាស្ត្រីមានចំនួនច្រើនជាងអ្នកបោះឆ្នោតជាបុរស ដោយសារ ចំនួនអ្នកបោះ ឆ្នោតជាស្ត្រីនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការមានចំនួនប្រមាណជាង ៥២,៥០% ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង
អ្នកស្រី **សឺនកេត សិរីលក្ខណ៍** អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រ ខុមហ្វ្រែល
ទូរស័ព្ទ ៖ ០១៧ ៤៩៤ ០០៤

<u>**បេសកម្ម**</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។